សុន្ទរកថារបស់ **លោក ទ៉ាដា តាកាយូគ**
លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាអង្គរអង្គ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង
ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**
**សូមគោរព ឯកឧត្តម ឡុង ផាត អភិបាលរងខេត្តព្រៃវែង!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាអង្គរអង្គនៅថ្ងៃនេះជាមួយនឹងវត្តមានរបស់ឯកឧត្តម ឡុង ផាត អភិបាលរងខេត្តព្រៃវែង។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស អង្គការ JHP ដែលបានសម្របសម្រួល និងអនុវត្តគម្រោងនេះ។

ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការជំនះនូវរាល់ឧបសគ្គក្នុងរយៈពេលពីរទស្សវត្សចុងក្រោយនេះបន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់។ សន្ទស្សន៍នៃអត្រាកំណើនសេដ្ឋកិច្ចបានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យអប់រំបានបន្តរីកចំរើនទាំងបរិមាណ និងគុណភាពពីមួយឆ្នាំទៅមួយឆ្នាំ។

ការធានានូវការទទួលបានការអប់រំកម្រិតបឋមសិក្សា គឺជាគោលដៅចម្បងមួយនាពេលបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំសូមធ្វើការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាតាមរយៈការជួយសាងសង់សាលារៀន ក៏ដូចជាបណ្តុះបណ្តាលគ្រូបង្រៀនជាដើមតាំងពីកំឡុងឆ្នាំ១៩៩០មកម្លេះ។

ខ្ញុំបានទទួលដំណឹងថាសិស្សានុសិស្សប្រមាណ១០៤នាក់ នៅសាលាបឋមសិក្សាអង្គរអង្គត្រូវរៀននៅក្នុងថ្នាក់រៀនដែលគ្មានសុវត្ថិភាព និងចាស់ទ្រុឌទ្រោមដោយសារទឹកជំនន់។ ចាប់ពីឆមាសក្រោយនេះតទៅ សិស្សានុសិស្សប្រមាណ១២០នាក់នឹងចាប់ផ្តើមរៀនសូត្រនៅក្នុងអគារសិក្សាថ្មីដែលសង់ក្នុងកម្ពស់២.៥ម៉ែត្រផុតពីដីមាន៤បន្ទប់ និងបន្ទប់អនាម័យ៤បន្ទប់នេះ។ គម្រោងនេះនឹងអនុញ្ញាតិឲ្យក្មួយៗសិស្សានុសិស្សទាំងអស់អាចសិក្សានៅក្នុងអគារសិក្សាថ្មីនេះដោយសុវត្ថិភាព និងផាសុខភាព ពិសេសនៅរដូវភ្លៀង។

ខ្ញុំសង្ឃឹមថា សិស្សានុសិស្សនៃសាលាបឋមសិក្សាអង្គរអង្គទាំងអស់នឹងអាចបញ្ចប់ការសិក្សារបស់ពួកក្មួយនៅក្នុងថ្នាក់រៀនដែលមានបរិស្ថានសិក្សាល្អប្រសើរ ដូចនេះសូមជួយថែរក្សាអគារនេះឲ្យបាននៅគង់វង្សល្អទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀត នូវទំនាក់ទំនងមិត្តភាពរវាង ប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!